**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

លេខ...០៦៧៤.....សហវ......

# សេចក្តីជូនដំណឹង

## ស្តីពី

## ការដាក់ឱ្យដំណើរការប្រព័ន្ធសន្ធានកម្ម រវាង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ជាមួយ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS)

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជូនដំណឹងដល់ក្រសួង-ស្ថាប័ន និង អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាំងអស់ ដែលកំពុងតែប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ជ្រាបថា យោងតាមផែនការរួមដំណាក់កាលទី៣ ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំរួចរាល់នូវប្រព័ន្ធសន្ធានកម្ម រវាងប្រព័ន្ធ FMIS ជាមួយនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) ក្នុងន័យទាញបញ្ចូលទិន្នន័យ និង បង្កើតប្រតិបត្តិការដោយស្វ័យប្រវត្តិក្នុងប្រព័ន្ធ FMIS លើចំណូលថវិកាដែលបានពីការប្រមូលចំណូលមិនមែនសារពើពន្ធ និង បានកត់ត្រារួចរាល់ក្នុងប្រព័ន្ធ NRMIS ។ ប្រព័ន្ធសន្ធានកម្មរវាងប្រព័ន្ធ FMIS និង ប្រព័ន្ធ NRMIS នេះ នឹងដាក់ឱ្យដំណើរការអនុវត្តចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២០ នេះតទៅ ។

ក្នុងន័យនេះ ក្រសួង-ស្ថាប័ន និង អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាំងអស់ដែលកំពុងប្រើប្រាស់ប្រព័ន្ធ FMIS **មិនតម្រូវឱ្យធ្វើការកត់ត្រាសលាកបត្របង់ចំណូលថវិកាតាមប្រព័ន្ធ FMIS ទៀតនោះទេសម្រាប់សលាកបត្រទាំងឡាយណាដែលបានបោះពុម្ពចេញពីប្រព័ន្ធ NRMIS** លើកលែងតែមានករណីដោយឡែកនៅមានសលាកបត្របង់ចំណូលថវិកាដែលរៀបចំខាងក្រៅប្រព័ន្ធ NRMIS គឺនៅរក្សាការចុះប្រតិបត្តិការចំណូលថវិកាតាមប្រព័ន្ធ FMIS ដដែល ។ ព័ត៌មាននៃការបង់ចំណូលថវិកាទាំងអស់ ដែលក្រសួង-ស្ថាប័ន ឬ អង្គភាពប្រមូលចំណូលមិនមែនសារពើពន្ធ ធ្វើការកត់ត្រានៅក្នុងប្រព័ន្ធ NRMIS នឹងត្រូវផ្ទេរចូលប្រព័ន្ធ FMIS ដោយស្វ័យប្រវត្តិតាមប្រព័ន្ធសន្ធានកម្ម ។

អាស្រ័យហេតុនេះ សូមក្រសួង-ស្ថាប័ន និង អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាំងអស់ ដែលកំពុងប្រើប្រាស់ប្រព័ន្ធ FMIS ជ្រាបជាព័ត៌មាន និង អនុវត្តតាមសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ថ្ងៃ ចន្ទ ៥ កើត ខែ បុស្ស ឆ្នាំ កុរ ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៩

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ក្រសួង ស្ថាប័ន
- អគ្គនាយកដ្ឋានរតនាគារជាតិ "ដើម្បីអនុវត្ត"
- ឯកសារ- កាលប្បវត្តិ

ផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥) ២៣ ៨៩០ ៦៦៦
Phone : (+855) 23 890 666